# ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា
# Cambodia Public Debt Statistical Bulletin








## លេខ ២៩ - Vol. 29

ទិន្នន័យត្រឹមដំណាច់ឆ្នាំ២០២៥ - Data as of Year-end 2025
រាជធានីភ្នំពេញ, ខែកុម្ភៈ ឆ្នាំ២០២៦ / Phnom Penh, February 2026

# អារម្ភកថា

ស្ថានភាពបំណុលសាធារណៈបច្ចុប្បន្នរបស់កម្ពុជា នៅតែត្រូវបានវាយតម្លៃថា ស្ថិតក្នុងភាពអាចគ្រប់គ្រងបាន ពោលគឺ នៅតែមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»** ។ ការរក្សាបាននូវចីរភាពបំណុលសាធារណៈនេះ គឺអាស្រ័យដោយកម្ពុជាមានប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈមួយដ៏រឹងមាំ ដែលមានជាអាទិ៍៖ ១) ក្របខ័ណ្ឌគតិយុត្ត, ២) គោលនយោបាយ, យុទ្ធសាស្ត្រ, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគ្រប់ជ្រុងជ្រោយ, ៣) សមត្ថភាពស្ថាប័ន និងធនធានមនុស្សគ្រប់គ្រាន់, និង ៤) ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងប្រតិបត្តិការ និងរក្សាទុកទិន្នន័យ ដើម្បីជាមូលដ្ឋាននៃការវិភាគ និងតាមដានហានិភ័យបំណុល។ល។

ជាក់ស្តែង, រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយភាពម៉ឺងម៉ាត់ និងប្រយ័ត្នប្រយែងខ្ពស់នូវ វិធានការជាយុទ្ធសាស្ត្រនានា ដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈជាបន្តបន្ទាប់ ជាពិសេស គោលការណ៍គន្លឹះទាំង ៥ សំដៅបន្តពង្រឹងប្រសិទ្ធភាពខ្ពស់ ទាំងការគ្រប់គ្រងបំណុលសាធារណៈ និងទាំងការគ្រប់គ្រងការវិនិយោគសាធារណៈ រួមមាន៖

១) ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន;
២) ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះ;
៣) ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម;
៤) ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាពខ្ពស់បំផុត; និង
៥) ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ទន្ទឹមនឹងការប្រកាន់ខ្ជាប់នូវគោលការណ៍ទាំង៥ ខាងលើ, ការផ្លាស់ប្តូរឆ្នាំគោលថ្មីនៃគណនេយ្យជាតិឆ្នាំ២០១៤ បាននិងកំពុងធ្វើឱ្យសមត្ថភាពខ្ចីរបស់កម្ពុជាកើនខ្ពស់ជាងមុន ដែលផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលអាចកៀរគរហិរញ្ញប្បទានពីការខ្ចីបានច្រើនបន្ថែមទៀត សម្រាប់យកមកបំពេញតម្រូវការវិនិយោគសាធារណៈក្នុងវិស័យអាទិភាពនានា សំដៅរួមចំណែកល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ក្នុងគោលបំណងបន្តលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងបំណុលសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និងបោះពុម្ពជាសៀវភៅចែកជូនស្ថាប័ននីតិប្បញ្ញត្តិ, ក្រសួងស្ថាប័នពាក់ព័ន្ធ, ស្ថានទូត, គ្រឹះស្ថានអប់រំ, ដៃគូអភិវឌ្ឍ, និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីប្រើប្រាស់តាមតម្រូវការជាក់ស្តែង ចំនួន ២៨ លើក រួចមកហើយ ក្នុងនោះ ប្រចាំឆមាស ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១ និងប្រចាំត្រីមាស ពីឆ្នាំ២០២២ ដល់បច្ចុប្បន្ន ព្រមទាំងបានផ្សព្វផ្សាយនៅលើគេហទំព័រផ្លូវការរបស់

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសាធារណជនអាចទាញយកបានតាមរយៈ៖ *http://mef.gov.kh/public-debt-bulletin.html* ឬ នៅលើគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល តាមរយៈ៖ *https://gdicdm.mef.gov.kh/en/cat/documents-and-publications/bulletins* ឬ តាមរយៈ QR Code នៅលើគម្របសៀវភៅព្រឹត្តិបត្រនេះ។

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ប្រចាំត្រីមាសនេះ ត្រូវបានរៀបរៀងឡើង ជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ដោយអនុលោមតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្តន៍ជាអន្តរជាតិ ដែលមានវិសាលភាពគ្របដណ្តប់តែលើទិន្នន័យស្តីពីបំណុលរបស់រដ្ឋប៉ុណ្ណោះ រួមមាន៖ ១) បំណុលសាធារណៈក្រៅប្រទេស, ២) បំណុលសាធារណៈក្នុងប្រទេស, និង ៣) ការផ្តល់ឥណទានរបស់រដ្ឋ ហើយមិនមានវិសាលភាពគ្របដណ្តប់លើបំណុលរបស់វិស័យឯកជនទេ។ ព្រឹត្តិបត្រនេះ ត្រូវបានញែកជា ២ ផ្នែក គឺ៖ **ផ្នែកទី១** សេចក្តីសង្ខេប និង**ផ្នែកទី២** ព័ត៌មាន/ទិន្នន័យលម្អិត ហើយបែងចែកទិន្នន័យជា ៥ ក្រុម គឺ៖ ១) សន្និធិបំណុល, ២) ការចុះកិច្ចព្រមព្រៀងឥណទាន, ៣) ការបោះផ្សាយលក់មូលបត្ររដ្ឋ, ៤) ការដកសាច់ប្រាក់, និង ៥) សេវាបំណុល (ការទូទាត់ជូនឥណទាយក និងការប្រមូលពីឥណាយិក ក្រោមក្របខ័ណ្ឌនៃការផ្តល់ឥណទានរបស់រដ្ឋ) ព្រមទាំងចាត់ចំណាត់ប្រភេទទៅតាម៖ ឥណទាយក/ឥណាយិក, រូបិយប័ណ្ណ, និងវិស័យ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមយ៉ាងមុតមាំថា ស្ថាប័នស្រាវជ្រាវ អ្នកវិភាគឯករាជ្យ ក៏ដូចជាតួអង្គពាក់ព័ន្ធដទៃទៀត នឹងយកព័ត៌មាន/ទិន្នន័យដែលមាននៅក្នុងព្រឹត្តិបត្រនេះ ទៅប្រើប្រាស់ ឬវិភាគ ប្រកបដោយវិជ្ជាជីវៈ និងមានក្រមសីលធម៌ខ្ពស់ ជៀសវាងការបកស្រាយខុសពីខ្លឹមសារពិត ដែលអាចនាំឱ្យសាធារណជនមានការភ័ន្តច្រឡំអំពីស្ថានភាពបំណុលសាធារណៈជាក់ស្តែងរបស់កម្ពុជា។ ក្នុងករណីមានចម្ងល់ ឬសំណួរពាក់ព័ន្ធផ្សេងៗ សូមទាក់ទងមកកាន់ក្រុមការងារបច្ចេកទេស តាមរយៈអ៊ីម៉ែល ddm@mef.gov.kh។

ជាទីបញ្ចប់, ខ្ញុំមានជំនឿថា ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជាលេខ ២៩ នេះ នឹងនៅតែបន្តទទួលបាននូវការគាំទ្រពីសំណាក់អ្នកអានទាំងឡាយ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមស្វាគមន៍នូវរាល់មតិយោបល់ស្ថាបនា ដើម្បីបន្តកែលម្អព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈលេខក្រោយៗ ឱ្យកាន់តែប្រសើរថែមទៀត។

*ថ្ងៃ អង្គារ ១៥កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩*

*រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០២៦*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

# Table of Contents


ទំព័រ / Page

**ផ្នែកទី១៖ សេចក្តីសង្ខេប / Part I: Executive Summary**

ស្ថានភាពបំណុលសាធារណៈ ត្រឹមដំណាច់ឆ្នាំ២០២៥ / ........ ១

Public Debt Situation as of Year-end 2025 ........ 1

**ផ្នែកទី២៖ ព័ត៌មាន/ទិន្នន័យលម្អិត / Part II: Detailed Information/Data**

**ជំពូក ១៖ ព័ត៌មានទូទៅ / Chapter 1: General Information**

ក- ពាក្យបំព្រួញ / A- Acronyms and Abbreviations ........ ៧ / 7

ខ- វិសាលភាព / B- Coverage ........ ៧ / 7

គ- ក្រុម និងចំណាត់ប្រភេទទិន្នន័យ / C- Grouping and Classification ........ ៧ / 7

ឃ- ប្រភពទិន្នន័យ / D- Sources ........ ៨ / 8

ង- ការប្តូររូបិយប័ណ្ណ / E- Currency Conversion ........ ៨ / 8

ច- គោលនយោបាយក្នុងការកែតម្រូវទិន្នន័យ / F- Revision Policy ........ ៨ / 8

ឆ- ការបោះផ្សាយ / G- Frequency and Time Lag ........ ៨ / 8

ជ- និយមន័យ / H- Definitions ........ ៩ / 9

**ជំពូក ២៖ តារាងស្ថិតិ / Chapter 2: Statistical Tables**

តារាងទី១៖ អត្រាប្តូរប្រាក់ / Table 1: Exchange Rates ........ ១៣ / 13

តារាងទី២៖ សូចនាករថ្លៃ និងហានិភ័យបំណុល / Table 2: Cost – Debt Risk Indicators ........ ១៤ / 14

**២.១៖ បំណុលសាធារណៈក្រៅប្រទេស / 2.1: Public External Debt**

តារាងទី៣៖ សន្និធិបំណុល / Table 3: Debt Stock ........ ១៥ / 15

តារាងទី៤៖ ការចុះកិច្ចព្រមព្រៀងឥណទាន / Table 4: Loan Signed ........ ១៦ / 16

តារាងទី៥៖ ការដកសាច់ប្រាក់ / Table 5: Disbursement ........ ១៧ / 17

តារាងទី៦៖ ការទូទាត់សេវាបំណុល / Table 6: Debt Service Payment ........ ១៨ / 18

**២.២៖ បំណុលសាធារណៈក្នុងប្រទេស / 2.2: Public Domestic Debt**

តារាងទី៧៖ បំណុលសាធារណៈក្នុងប្រទេស / Table 7: Public Domestic Debt ........ ១៩ / 19

**២.៣៖ ការផ្តល់ឥណទានរបស់រដ្ឋ / 2.3: Government Lending**

តារាងទី៨៖ ការផ្តល់ឥណទានរបស់រដ្ឋ / Table 8: Government Lending ........ ២០ / 20

**២.៤៖ ការព្យាករ / 2.4: Projections**

តារាងទី៩៖ ព្យាករណ៍ការទូទាត់សេវាបំណុលក្រៅប្រទេសប្រចាំខែ តាមរូបិយប័ណ្ណ ក្នុងឆ្នាំ២០២៦ / ........ ២១

Table 9: Projections of Monthly External Debt Service Payment by Currency in 2026 ........ 21

តារាងទី១០៖ព្យាករណ៍បំណុលសាធារណៈក្រៅប្រទេស / ........ ២២

Table 10: Projections of Public External Debt ........ 22

**ជំពូក ៣៖ ក្រាហ្វ / Chapter 3: Graphs**

ក្រាហ្វទី១៖ ការវិភាគចីរភាពបំណុល / Graph 1: Debt Sustainability Analysis ( DSA ) ........ ២៣ / 23

ក្រាហ្វទី២៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំឆ្នាំដោយផ្អែកលើសន្និធិបំណុលត្រឹមដំណាច់ឆ្នាំ២០២៥ ........ ២៤

Graph 2: Redemption Profile based on Debt Stock as of Year-end 2025 ........ 24

ក្រាហ្វទី៣៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំខែសម្រាប់ឆ្នាំ២០២៦-២០៤០ / ........ ២៥

Graph 3: Projections of Monthly Debt Service Payment for 2026-2040 ........ 25

# ផ្នែកទី ១
# សេចក្តីសង្ខេប

# Part I
# Executive Summary

# ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រឹមដំណាច់ឆ្នាំ២០២៥

# Cambodia's Public Debt Situation as of Year-end 2025

## ១. បំណុលសាធារណៈ

### ១.១ សន្និធិបំណុល

ដោយគិតទាំងបំណុលមរតក, ត្រឹមដំណាច់ឆ្នាំ២០២៥ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួន ***១៣,០៥ ប៊ីលានដុល្លារអាមេរិក*** ក្នុងនោះ៖ ***៩៨%*** ត្រូវនឹងប្រមាណ ***១២,៨១ ប៊ីលានដុល្លារអាមេរិក*** ជាបំណុលសាធារណៈក្រៅប្រទេស (ក្របខ័ណ្ឌទ្វេភាគីប្រមាណ ***៦០%*** និងក្របខ័ណ្ឌពហុភាគីប្រមាណ ***៤០%***) និង ***២%*** ត្រូវនឹងប្រមាណ ***២៤៦,៨៣ លានដុល្លារអាមេរិក*** ជាបំណុលសាធារណៈក្នុងប្រទេស។ សមាសភាគបំណុលសាធារណៈទាំងនេះ រួមមាន៖ ***៤៧%*** ជាដុល្លារអាមេរិក, ***១៧%*** ជាអេសដេអ៊ែ, ***១០%*** ជាយេនជប៉ុន, ***១០%*** ជាយ័នចិន, ***៩%*** ជាអឺរ៉ូ, និង ***៧%*** ទៀត ជារូបិយវត្ថុជាតិ និងរូបិយប័ណ្ណផ្សេងៗ។

## I. Public Debt

### 1.1 Debt Stock

As of Year-end 2025, including the old debt, Cambodia has a total public debt stock of **USD 13.05 billion** in which **98%** or approximately **USD 12.81 billion** is public external debt (comprising of **60%** from Bilateral Development Partners - DPs and **40%** from Multilateral DPs) and **2%** or **USD 246.83** million is public domestic debt. The composition of the public debt stock is comprised of USD **47%**, SDR **17%**, JPY **10%**, CNY **10%**, EUR **9%**, and local and other currencies **7%**.

### ១.២ ការចុះកិច្ចព្រមព្រៀងឥណទាន

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងឥណទានសម្បទានថ្មី ជាមួយដៃគូអភិវឌ្ឍនានា សរុបចំនួន ***៩២៤,៣៥ លានដុល្លារអាមេរិក*** សមមូលនឹង ***៦៧១,៣៣ លានអេសដេអ៊ែ***។ ជារួម, នៅក្នុងឆ្នាំ២០២៥ នេះ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងឥណទានថ្មីជាមួយដៃគូអភិវឌ្ឍនានា សរុបចំនួន ***១ ២២៥,៥៣ លានដុល្លារអាមេរិក*** សមមូលនឹង ***៨៩០,០៦ លានអេសដេអ៊ែ*** ស្មើនឹងប្រមាណ ***៤៥%*** នៃពិតានដែលច្បាប់អនុញ្ញាត ***(២ ០០០ លានអេសដេអ៊ែ)*** ក្នុងនោះ ក្របខ័ណ្ឌទ្វេភាគី ***៣៣%*** និងក្របខ័ណ្ឌពហុភាគី ***៦៧%***។ បើធៀបនឹងឆ្នាំ២០២៤ ការចុះកិច្ចព្រមព្រៀងឥណទានសម្បទានថ្មីក្នុងឆ្នាំ២០២៥ នេះ មានការថយចុះប្រមាណ ***៣១%***។

### 1.2 Loan Signed

In Q4 2025, the Royal Government of Cambodia (RGC) has signed new concessional loans with DPs in the total amount of **USD 924.35 million** equivalent to **SDR 671.33 million**. Overall, in 2025, total new loan signed with DPs is **USD 1,225.53 million** equivalent to **SDR 890.06 million**, accounting for **45%** of the ceiling permitted by Law (**SDR 2,000 million**) of which **33%** is signed with Bilateral DPs and **67%** is signed with Multilateral DPs. The loan signed in 2025 decreased by approximately **31%** compared to 2024.

ឥណទានទាំងនេះ សុទ្ធសឹងជាឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដោយមានធាតុអំណោយជាមធ្យមប្រមាណ ***៣៩,៣%***។ គោលដៅនៃការចុះកិច្ចព្រមព្រៀងឥណទានថ្មីទាំងនេះ គឺសម្រាប់បំពេញតម្រូវការហិរញ្ញប្បទានក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើន

Overall, all the loans are highly concessional with an average grant element of around **39.3%**. The purpose of these new signed loans is to finance public investment projects in the priority sectors that support long-term sustainable economic growth and

រយៈពេលវែង និងបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម។

increase economic productivity/production.

### ១.៣ ការបោះផ្សាយលក់មូលបត្ររដ្ឋ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ រាជរដ្ឋាភិបាលបានបោះផ្សាយលក់មូលបត្ររដ្ឋ សរុបចំនួន ***៤៨៣,២១ ប៊ីលានរៀល*** ត្រូវនឹងប្រមាណ ***១២០,៤១ លានដុល្លារអាម៉េរិក*** ក្នុងនោះ មូលបត្ររដ្ឋជាប្រាក់រៀលមានចំនួន ***២០២,៣០ ប៊ីលានរៀល*** និងមូលបត្ររដ្ឋជាប្រាក់ដុល្លាអាម៉េរិកមានចំនួន ***៧០ លានដុល្លារអាម៉េរិក*** ។

### 1.3 Government Securities Issuance

In Q4 2025, the RGC has issued government securities in total amount of **KHR 483.21 billion** approximately equivalent to **USD 120.41** million, of which, KHR government securities amounted to **KHR 202.30 billion** and USD government securities amounted to **USD 70 million.**

ជារួម, នៅក្នុងឆ្នាំ២០២៥ នេះ រាជរដ្ឋាភិបាលបានបោះផ្សាយលក់មូលបត្ររដ្ឋ សរុបចំនួន ***៦៩១,២១ ប៊ីលានរៀល*** ត្រូវនឹងប្រមាណ ***១៧២,២៤ លានដុល្លារអាម៉េរិក*** ត្រូវនឹងប្រមាណ ***១៣៨%*** នៃពិតានកំណត់ក្នុងច្បាប់ ***(៥០០ ប៊ីលានរៀល)***[១] ក្នុងនោះ មូលបត្ររដ្ឋជាប្រាក់រៀលមានចំនួន ***៤១០,៣០ ប៊ីលានរៀល*** និងមូលបត្ររដ្ឋជាប្រាក់ដុល្លារអាម៉េរិកមានចំនួន ***៧០ លានដុល្លារអាម៉េរិក*** ដើម្បីធ្វើហិរញ្ញប្បទានគាំទ្រគម្រោងវិនិយោគសាធារណៈ, ការអនុវត្តវិធានការគោលនយោបាយគន្លឹះរបស់រាជរដ្ឋាភិបាល និងរក្សាតុល្យភាពថវិកាជាតិ សំដៅលើកស្ទួយកំណើន និងផលិតភាពសេដ្ឋកិច្ចជាតិ។

Overall, in 2025, the RGC has issued government securities in total amount of **KHR 691.21 billion**, equivalent to **USD 172.24 million** accounting for **138%** of the ceiling in the budget law (**KHR 500 billion**)[1], of which, KHR government securities amounted to **KHR 410.30 billion** and USD government securities amounted to **USD 70 million,** for financing supports to the public investment, implementing the RGC's priority policy measures and maintaining the national budget balance for economic and productivity.

*[១] ជាកម្មវត្ថុនៃការធ្វើនិយ័តភាវូបនីយកម្មក្នុងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។*

*[1] Subject to be regularized in budget settlement law 2025.*

### ១.៤ ការដកសាច់ប្រាក់

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីឥណទានសម្បទាន ដែលបានចុះកិច្ចព្រមព្រៀងកន្លងមក សរុបចំនួន ***៤១២,៧១ លានដុល្លារអាម៉េរិក***។ ជារួម, នៅក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់សរុបចំនួនប្រមាណ ***១,០៤ ប៊ីលានដុល្លារអាម៉េរិក*** ក្នុងនោះ៖ ក្របខ័ណ្ឌទ្វេភាគីមានប្រមាណ ***៤៤%*** និងក្របខ័ណ្ឌពហុភាគីមានប្រមាណ ***៥៦%***។ សាច់ប្រាក់ទាំងនេះ ត្រូវបានប្រើប្រាស់ជាក់ស្តែងទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ***៧៩%*** និងវិស័យអាទិភាពចំពោះមុខផ្សេងទៀត (មិនមែនហេដ្ឋារចនាសម្ព័ន្ធ) ***២១%***។

### 1.4 Disbursement

In Q4 2025, the RGC has disbursed **USD 412.71 million** from the existing concessional loans. Overall, in 2025, the RGC has disbursed approximately **USD 1.04 billion** from existing concessional loans of which: **44%** is from Bilateral DPs and **56%** is from Multilateral DPs. **79%** of disbursed amount is used for infrastructure and **21%** for other priority sectors (non-infrastructure).

ដោយឡែក, បើធៀបនឹងឆ្នាំ២០២៤ ការដកសាច់ប្រាក់ជាក់ស្តែងនៅក្នុងឆ្នាំ២០២៥ នេះ មានការថយចុះប្រមាណ ***៣៣%***។

The actual disbursement in 2025 decreased by approximately **33%** compared to 2024.

### ១.៥ ការទូទាត់សេវាបំណុល

### 1.5 Debt Service Payment

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានទូទាត់សេវាបំណុលសរុបចំនួន ***១១៥,២៥ លានដុល្លារអាមេរិក***។ ជារួម, នៅក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានទូទាត់សេវាបំណុលសរុបចំនួន ***៦៧៨,៣០ លានដុល្លារអាមេរិក*** រួមមាន៖ ១) ក្របខ័ណ្ឌបំណុលសាធារណៈក្រៅប្រទេសមានចំនួនប្រមាណ ***៦៣២,៥៦ លានដុល្លារអាមេរិក*** ក្នុងនោះ៖ ប្រាក់ដើម ***៥០០,២៤ លានដុល្លារអាមេរិក*** និងការប្រាក់និងកម្រៃផ្សេងៗ ***១៣២,៣២ លានដុល្លារអាមេរិក***, និង ២) ក្របខ័ណ្ឌបំណុលសាធារណៈក្នុងប្រទេស មានចំនួនប្រមាណ ***៤៥,៧៥ លានដុល្លារអាមេរិក*** ក្នុងនោះ៖ ប្រាក់ដើម ***៤០,៧៥ លានដុល្លារអាមេរិក*** និងការប្រាក់ ***៥ លានដុល្លារអាមេរិក***។

In Q4 2025, the RGC has paid debt service in the amount of **USD 115.25 million**. Overall, in 2025, the RGC has paid debt service in the amount of **USD 678.30 million** as follows: 1) equivalent to **USD 632.56 million** is for public external debt which: principal **USD 500.24 million** and interest and other fees **USD 132.32 million** and 2) equivalent to **USD 45.75 million** for public domestic debt which: principal **USD 40.75 million** and interest **USD 5 million.**

ដោយឡែក, បើធៀបនឹងឆ្នាំ២០២៤ ការទូទាត់សេវាបំណុលសរុបក្នុងឆ្នាំ២០២៥ នេះ មានកំណើនប្រមាណ ***២១%***។

The debt service payments in 2025 increased by approximately **21%** compared to 2024.

### ១.៦ សូចនាករបំណុលគន្លឹះៗ

### 1.6 Debt Indicators

ផ្អែកតាមលទ្ធផលបឋមនៃការវិភាគចីរភាពបំណុលតាមមូលដ្ឋានទិន្នន័យប៉ាន់ស្មានឆ្នាំ២០២៥ បង្ហាញថា ស្ថានភាពបំណុលសាធារណៈកម្ពុជា បន្តរក្សានូវ ***«ចីរភាព»*** និង ***«ហានិភ័យកម្រិតទាប»*** ដដែល ដោយរាល់សូចនាករបំណុលគន្លឹះៗទាំងអស់សុទ្ធតែស្ថិតក្រោមអនុបាតគោល ក្នុងនោះអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុបធៀបនឹង ផសស មានត្រឹមកម្រិត ***១៨,៧%*** ធៀបនឹងអនុបាតគោល ***៥៥%*** និងអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស មានត្រឹមកម្រិត ***១៨,៣%*** ធៀបនឹងអនុបាតគោល ***៤០%***។

The preliminary results of the 2025 Estimated Debt Sustainability Analysis (DSA) shows that Cambodia's public debt situation continues to remain **"sustainable"** and **"low risk"** of debt distress, with all key debt indicators below the thresholds, of which the Present Value of Total Public Debt to GDP, is at **18.7%** compared to the **55%** threshold and the Present Value of Public and Publicly Guaranteed External Debt to GDP, is at **18.3%** compared to the **40%** threshold.

## ២. ការផ្តល់ឥណទានរបស់រដ្ឋ

## II. Government Lending

### ២.១ សន្និធិបំណុល

### 2.1 Debt Stock

គិតត្រឹមដំណាច់ឆ្នាំ២០២៥ សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋសរុបចំនួនប្រមាណ ***៣,០២ ប៊ីលានដុល្លារអាមេរិក***។

As of Year-end 2025, the debt stock of government lending accounts for approximately **USD 3,02 billion.**

## ២.២ ការផ្តល់ឥណទាន

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ រាជរដ្ឋាភិបាលបានពុំមានការចុះកិច្ចព្រមព្រៀងផ្តល់ឥណទានថ្មីនោះទេ។

ជារួម, នៅក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងផ្តល់ឥណទានជាមួយឥណាយិកសរុបចំនួន ***១៦៩,៥០ លានដុល្លារអាមេរិក***។

ដោយឡែក, បើធៀបនឹងឆ្នាំ២០២៤ ការចុះកិច្ចព្រមព្រៀងផ្តល់ឥណទានថ្មីសរុបក្នុងឆ្នាំ២០២៥នេះ មានការថយចុះប្រមាណ ***៦៥%*** ។

## 2.2 Direct Lending and On-lending

In Q4 2025, no new government lending and on-lending agreement were signed.

Overall, in 2025, the RGC has signed government lending and on-lending agreement with debtor in total of **USD 169.50 million.**

The total signed government lending in 2025 decreased by approximately **65%** compared to 2024.

## ២.៣ ការដកសាច់ប្រាក់

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ឥណាយិកបានដកសាច់ប្រាក់យកទៅប្រើប្រាស់ជាក់ស្តែងសរុបចំនួន ***១៣០,៤០ លានដុល្លារអាមេរិក***។ ជារួម, នៅក្នុងឆ្នាំ២០២៥ ការដកសាច់ប្រាក់ជាក់ស្តែងមានចំនួន ***៣៣១,៩៩ លានដុល្លារអាមេរិក***។

ដោយឡែក, បើធៀបទៅនឹងឆ្នាំ២០២៤ ការដកសាច់ប្រាក់ជាក់ស្តែងសរុបនៅក្នុងឆ្នាំ២០២៥ នេះ មានកំណើនប្រមាណ ***៣%***។

## 2.3 Disbursement

In Q4 2025, **USD 130.40 million** has been disbursed to debtors. Overall, in 2025, **USD 331.99 million** has been disbursed to debtors.

The actual disbursement in 2025 increased by approximately **3%** compared to 2024.

## ២.៤ ការប្រមូលសេវាបំណុល

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានប្រមូលសេវាបំណុលសរុបចំនួន ***៥០,២៧ លានដុល្លារអាមេរិក***។ ជារួម, នៅក្នុង ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានប្រមូលសេវាបំណុលសរុបចំនួន ***១៨៧,១៣ លានដុល្លារអាមេរិក*** (ប្រាក់ដើមមានចំនួន ***១៣២,៥១ លានដុល្លារអាមេរិក*** និងការប្រាក់និងកម្រៃផ្សេងៗមានចំនួន ***៥៤,៦២ លាន ដុល្លារអាមេរិក***) ពីឥណាយិកក្នុងវិស័យសាធារណៈនិងក្នុងវិស័យ ឯកជន។

ដោយឡែក, បើធៀបនឹងឆ្នាំ២០២៤ ការប្រមូលសេវាបំណុលជាក់ស្តែងសរុបនៅក្នុងឆ្នាំ២០២៥ នេះ មានការកំណើនប្រមាណ ***៣៨%*** ។

## 2.4 Debt Service Collection

In Q4 2025, the RGC has collected debt service in the amount of **USD 50.27 million.** Overall, in 2025, the RGC has collected debt services in the amount of **USD 187.13 million** (principal **USD 132.51 million** and interest includes other fees **USD 54.62 million**) from public sector and private sector.

The debt service collection in 2025 increased by approximately **38%** compared to 2024.

## ស្ថានភាពបំណុលសាធារណៈ ត្រឹមដំណាច់ឆ្នាំ២០២៥ / Public Debt Situation As of Year-end 2025

ឯកតា៖ លានដុល្លារអាម៉េរិក / Unit: USD Million

| បរិយាយ / Description | អនុបាតគោល/ Threshold | 2024 | Q1 to Q3 2025 | Q4-2025 | 2025e |
|---|---|---|---|---|---|
| **I. សន្និធិបំណុល / Debt Stock** [1] | | **12,059.34** | **12,653.93** | **13,054.04** | **13,054.04** |
| - ក្រៅប្រទេស / External | | 11,944.23 | 12,520.44 | 12,807.22 | 12,807.22 |
| - ក្នុងប្រទេស / Domestic | | 115.11 | 133.49 | 246.83 | 246.83 |
| **II. ការចុះកិច្ចព្រមព្រៀងឥណទាន / Loan Signed** | | **1,781.09** | **297.77** | **924.35** | **1,225.53** |
| **III. ការបោះផ្សាយលក់មូលបត្ររដ្ឋ / Government Securities Issuance** | | **74.86** | **51.87** | **120.41** | **172.24** |
| **IV. ការដកសាច់ប្រាក់ / Disbursement** | | **1,543.68** | **624.93** | **412.71** | **1,037.64** |
| **V. ការទូទាត់សេវាបំណុល / Debt Service Payment** | | **559.22** | **563.06** | **115.25** | **678.30** |
| **1. ក្រៅប្រទេស / External** [2] | | **543.24** | **525.07** | **107.48** | **632.56** |
| - ប្រាក់ដើម / Principal | | 419.14 | 421.22 | 79.02 | 500.24 |
| - ការប្រាក់ និងកម្រៃផ្សេងៗ / Interest and Other Fees | | 124.10 | 103.86 | 28.46 | 132.32 |
| **2. ក្នុងប្រទេស / Domestic** | | **15.98** | **37.98** | **7.76** | **45.75** |
| - ប្រាក់ដើម / Principal | | 12.72 | 33.81 | 6.94 | 40.75 |
| - ការប្រាក់ / Interest | | 3.27 | 4.18 | 0.82 | 5.00 |
| **សូចនាករ / Indicator** [3] | | | | | |
| 1.តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប / PV of Total Public Debt | | | | | |
| -ធៀបនឹង ផសស / to GDP | 55 | 18.3 | | | 18.7 |
| 2. តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស / PV of Public and Publicly Guaranteed External Debt | | | | | |
| - ធៀបនឹង ផសស / to GDP | 40 | 18.1 | | | 18.3 |
| - ធៀបនឹង ការនាំចេញ / to Exports | 180 | 26.9 | | | 26.1 |
| 3. សេវាបំណុលសាធារណៈក្រៅប្រទេស / Public and Publicly Guaranteed External Debt Service | | | | | |
| - ធៀបនឹង ការនាំចេញ / to Exports | 15 | 1.7 | | | 1.8 |
| - ធៀបនឹង ចំណូលថវិកាជាតិ / to Revenue | 18 | 7.6 | | | 8.0 |

កំណត់សម្គាល់ / Technical Notes:

*(1)- គិតបញ្ចូលទាំងសន្និធិបំណុលមរតក (ដែលបានដោះស្រាយរួច និងកំពុងចរចាដោះស្រាយ) / Including old debts (rescheduled and under negotiation).*

*(2)- គិតបញ្ចូលទាំងការទូទាត់សេវាបំណុលនៃបំណុលមរតកដែលបានដោះស្រាយរួច / Including rescheduled old debts.*

*(3)- តួលេខ ផសស គឺផ្អែកតាមតួលេខក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ (ខែមេសា ឆ្នាំ២០២៥)*

# ស្ថានភាពបំណុលសាធារណៈ ត្រឹមដំណាច់ឆ្នាំ២០២៥ / Public Debt Situation as of Year-end 2025

## ១. សន្និធិបំណុលសាធារណៈ គិតត្រឹមដំណាច់ឆ្នាំ២០២៥ / 1. Public Debt Stock as of Year-end 2025




សរុប / Total = USD 13,054.04 mil.

## ២. សន្និធិបំណុលសាធារណៈតាមរូបិយប័ណ្ណ ត្រឹមដំណាច់ឆ្នាំ២០២៥ / 2. Public Debt Stock by Currency as of Year-end 2025




## ៣. សន្និធិបំណុលសាធារណៈសរុប / 3. Total of Public Debt Stock




## ៤. ការចុះកិច្ចព្រមព្រៀងឥណទានក្នុងឆ្នាំ២០២៥ / 4. Loan Signed in 2025




## ៥. ការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងឆ្នាំ២០២៥ / 5. Government Securities Issuance in 2025




## ៦. ការដកសាច់ប្រាក់ក្នុងឆ្នាំ២០២៥ / 6. Disbursement in 2025




សរុប / Total = USD 1,037.64 mil.

## ៧. ការទូទាត់សេវាបំណុលក្នុងឆ្នាំ២០២៥ / 7. Debt Service Payment in 2025




សរុប / Total USD 678.30 mil.

ប្រាក់ដើម / Principal    ការប្រាក់ និងកម្រៃផ្សេងៗ / Interest and other fees

# ផ្នែកទី ២
# ព័ត៌មាន/ទិន្នន័យលម្អិត

# Part II
# Detailed Information/Data

# ជំពូក ១
# ព័ត៌មានទូទៅ

# Chapter 1
# General Information

## ក- ពាក្យបំព្រួញ / A- Acronyms and Abbreviations

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AIF | ASEAN Infrastructure Fund | មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន |
| AIIB | Asian Infrastructure Investment Bank | ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី |
| CNY | Chinese Yuan Renminbi | យ័នចិន |
| EUR | Euro | អឺរ៉ូ |
| EIB | European Investment Bank | ធនាគារវិនិយោគអឺរ៉ុប |
| GDP | Gross Domestic Product | ផសស - ផលិតផលក្នុងស្រុកសរុប |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| JPY | Japanese Yen | យេនជប៉ុន |
| KHR | Khmer Riel | រៀលខ្មែរ |
| KRW | Korean Won | វ៉ុនកូរ៉េ |
| NDF | Nordic Development Fund | មូលនិធិអភិវឌ្ឍន៍ណ័រឌីក |
| OFID | OPEC Fund for International Development | មូលនិធិអូប៉ិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| SDR | Special Drawing Rights | អេសដេអ៊ែ |
| THB | Thai Baht | បាតថៃ |
| USD | United States Dollar | ដុល្លារអាម៉េរិក |
| WB | World Bank | ធនាគារពិភពលោក |

## ខ- វិសាលភាព

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ មានវិសាលភាពគ្របដណ្តប់តែលើទិន្នន័យស្តីពីបំណុលរបស់រដ្ឋប៉ុណ្ណោះរួមមាន៖ ១) បំណុលសាធារណៈក្រៅប្រទេស, ២) បំណុលសាធារណៈក្នុងប្រទេស, និង ៣) ការផ្តល់ឥណទានរបស់រដ្ឋ។ ព្រឹត្តិបត្រនេះ មិនមានវិសាលភាពគ្របដណ្តប់លើបំណុលរបស់វិស័យឯកជនទេ។

## B. Coverage

This public debt statistical bulletin covers only public debt data on: 1) Public External Debt, 2) Public Domestic Debt, and 3) Government Lending. This bulletin does not cover data on private debt.

## គ- ក្រុម និងចំណាត់ប្រភេទទិន្នន័យ

ទិន្នន័យក្នុងព្រឹត្តិបត្រនេះ ត្រូវបានបែងចែកជា ៥ ក្រុម គឺ៖ ១) សន្និធិបំណុល, ២) ការចុះកិច្ចព្រមព្រៀងឥណទាន, ៣) ការបោះផ្សាយលក់មូលបត្ររដ្ឋ ៤) ការដកសាច់ប្រាក់, និង ៥) សេវាបំណុល (ការទូទាត់ និងការប្រមូល)។ ទិន្នន័យទាំងនេះ ជាតម្លៃចារឹក។

បន្ថែមលើនេះ ទិន្នន័យត្រូវបានចាត់ចំណាត់ប្រភេទទៅតាម៖ ១) ឥណទាយក/ឥណាយិក, ២) រូបិយប័ណ្ណ, និង ៣) វិស័យ។

## C. Grouping and Classification

Data in this bulletin are grouped in 5 categories: 1) Debt Stock, 2) Loan Signed, 3) Government Securities Issuance 4) Disbursement, and 5) Debt Service (Payment and Collection), expressed in Face Value.

Furthermore, the data are classified by: 1) Creditor/Debtor, 2) Currency, and 3) Sector.

## ឃ- ប្រភពទិន្នន័យ

ទិន្នន័យ សម្រាប់ប្រើជាមូលដ្ឋានក្នុងការរៀបចំព្រឹត្តិបត្រនេះមានប្រភពដូចខាងក្រោម៖

- ទិន្នន័យបំណុល៖ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ទិន្នន័យម៉ាក្រូសេដ្ឋកិច្ច៖ អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ទិន្នន័យអត្រាប្តូរប្រាក់៖ ធនាគារជាតិនៃកម្ពុជា។

## ខ- ការប្តូររូបិយប័ណ្ណ

ការប្តូររូបិយប័ណ្ណ ត្រូវបានអនុវត្តតាមវិធីសាស្ត្រជាបទដ្ឋានបច្ចេកទេសអន្តរជាតិ ដូចខាងក្រោម៖

- សន្និធិបំណុល៖ គិតតាមអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃចុងគ្រា។
- ការចុះកិច្ចព្រមព្រៀងឥណទាន៖ គិតតាមអត្រាប្តូរប្រាក់ផ្លូវការនៅចុងត្រីមាសនីមួយៗ។
- ការបោះផ្សាយលក់មូលបត្ររដ្ឋ៖ គិតតាមអត្រាប្តូរប្រាក់ផ្លូវការនៅចុងត្រីមាសនីមួយៗ។
- ការដកសាច់ប្រាក់៖ គិតតាមអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃដកសាច់ប្រាក់ជាក់ស្តែង។
- សេវាបំណុល៖ គិតតាមអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃទូទាត់/ប្រមូលសេវាបំណុលជាក់ស្តែង។
- ការព្យាករ៖ គិតតាមអត្រាប្តូរប្រាក់ផ្លូវការនៅចុងត្រីមាសនីមួយៗ។

## D. Sources

The sources of data used for preparing this bulletin are as below:

- Debt data: General Department of International Cooperation and Debt Management, Ministry of Economy and Finance.
- Macro-economic data: General Department of Policy, Ministry of Economy and Finance.
- Exchange rates data: National Bank of Cambodia.

## E. Currency Conversion

The international best practice approach has been applied for the currency conversion as follows:

- Debt Stock: converted by the official exchange rates at end-period.
- Loan signed: converted by the official exchange rates at end of each quarter.
- Government Securities Issuance: converted by the official exchange rates at end of each quarter.
- Disbursement: converted by the official exchange rates on actual disbursement date.
- Debt Service: converted by the official exchange rates on actual debt service payment collection date.
- Projections: converted by the official exchange rates at end of each quarter.

## ច- គោលនយោបាយក្នុងការកែតម្រូវទិន្នន័យ

តួលេខមួយចំនួននៅក្នុងព្រឹត្តិបត្រនេះ ត្រូវបានកែតម្រូវពីតួលេខ ដែលបានរាយការណ៍កន្លងមក ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយក៏អាចនឹងត្រូវកែតម្រូវនៅក្នុងការបោះផ្សាយលើកក្រោយផងដែរ។ តួលេខទាំងឡាយណាដែលមាន គូសបន្ទាត់ពីក្រោម បញ្ជាក់ថា ជាតួលេខដែលបានកែតម្រូវ។

## F. Revision Policy

Some figures in this bulletin have been revised from the figures previously reported by the Ministry of Economy and Finance and might also be revised in the next edition. The figures with underline are the revised figures.

## ឆ- ការបោះផ្សាយ

ការបោះផ្សាយព្រឹត្តិបត្រនេះ ធ្វើឡើងរៀងរាល់ត្រីមាសក្នុងរយៈពេលមិនលើសពី ២ខែ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។

## ជ- និយមន័យ

និយមន័យនៃវាក្យសព្ទគន្លឹះៗ ដែលប្រើប្រាស់ក្នុងព្រឹត្តិបត្រនេះ មានដូចខាងក្រោម៖

- **បំណុលសាធារណៈក្រៅប្រទេស៖** សំដៅដល់បំណុលក្រៅប្រទេសរបស់រដ្ឋដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយគិតបញ្ចូលទាំងបំណុលដែលមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បំណុលនេះ មានតែការខ្ចីឥណទានសម្បទាន ពីដៃគូអភិវឌ្ឍទ្វេភាគី និងពហុភាគីក្រៅប្រទេសប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលផងដែរនូវឧបករណ៍បំណុលផ្សេងទៀតដូចជាមូលបត្ររដ្ឋនៅក្រៅប្រទេសជាដើម ក្នុងករណីរាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។
- **បំណុលសាធារណៈក្នុងប្រទេស៖** សំដៅដល់បំណុលក្នុងប្រទេសរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយគិតបញ្ចូលនូវបំណុលដែលមានការធានាពីរដ្ឋ។
- **ការផ្តល់ឥណទានរបស់រដ្ឋ៖** សំដៅដល់ការឱ្យប្រាក់ខ្ចីដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល, សហគ្រាសសាធារណៈ, ក្រុមហ៊ុនចម្រុះ ដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលដៅជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ការផ្តល់ឥណទានរបស់រដ្ឋមាន ២ទម្រង់ រួមមាន៖ ការផ្តល់ឥណទានផ្ទាល់ ដោយប្រើថវិការដ្ឋ និងការផ្តល់ឥណទានបន្តដោយប្រើហិរញ្ញប្បទានដែលរដ្ឋខ្ចីពីគេ។
- **ការដកសាច់ប្រាក់៖** សំដៅដល់សាច់ប្រាក់ ដែលឥណទាយកបានអនុញ្ញាតឱ្យឥណាយិកដកយកមកប្រើប្រាស់ជាក់ស្តែងក្នុងការអនុវត្តគម្រោង/កម្មវិធី ។
- **សេវាបំណុល៖** សំដៅដល់ការទូទាត់ប្រាក់ដើម ការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀត នៃកាតព្វកិច្ចបំណុល។

## G. Frequency and Time Lag

The bulletin will be published on a quarterly basis within time lag of 2 months.

## H. Definitions

Terminologies used in this bulletin are defined as follows:

- **Public External Debt:** refers to the external debt of the central government incurred under the applicable laws including publicly guaranteed debt. In Cambodia's current context, the public external debt comprises only concessional loans from bilateral and multilateral external development partners. However, this debt, in the future, would also include other instruments such as international bonds in case of issuance decided by the RGC.
- **Public Domestic Debt:** refers to the internal debt of the central government incurred under the applicable laws including publicly guaranteed debt.
- **Government Lending:** refers to the credits provided by the government to state-owned enterprises, public institutions, state minority-owned companies, and banking and financial institutions for the purpose of supporting socio-economic development. Government Lending is categorized into 2 forms which are: Direct lending that provides credit using government budget and On-lending that provides credit using financing from government's borrowing.
- **Disbursement:** refers to proceeds or cash a creditor agreed with a debtor on the withdrawal for actual expenses in implementing a project/program.
- **Debt Service:** refers to the payment of principal, interest, and other related fees of debt obligation.

- **សន្និធិបំណុល៖** សំដៅដល់ទំហំបំណុលជាក់ស្តែង ដែល ឥណាយិកមិនទាន់ទូទាត់ជូនឥណទាយក។ ជាទូទៅ, សន្និធិបំណុល ស្មើនឹងការបោះផ្សាយលក់មូលបត្ររដ្ឋ បូកនឹងការដកសាច់ប្រាក់សរុប ដកឱ្យ៖ ការបង្វែរសាច់ប្រាក់ទៅឥណទាយក និងការទូទាត់ប្រាក់ដើមសរុប។ ជាករណីពិសេស សម្រាប់កម្ពុជា សន្និធិបំណុលសាធារណៈក្រៅប្រទេស ស្មើនឹង៖ ការដកសាច់ប្រាក់សរុប ដកឱ្យការបង្វែរ សាច់ប្រាក់ទៅដៃគូអភិវឌ្ឍវិញ, ការទូទាត់ប្រាក់ដើមសរុប, និងបំណុលដែលបានលុបដោយដៃគូអភិវឌ្ឍ បូកនឹង បំណុលមរតកដែលបានចរចាដោះស្រាយរួចហើយកំពុងសង និងបំណុលមរតកដែលកំពុងចរចាដោះស្រាយ។

